75

# ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី ៣៣៣

លេខៈ ២០០

ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ **នាមនាមប្រជារាស្ត្រខ្មែរ**

<u>សាលដីកា</u> **តុលាការកំពូល**

លេខៈ ៥៨ បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៤

ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឌិត** | **មុន្ទី** | ជាប្រធាន |
| ២-លោក | ស៊ិន | ឌីម | ជាចៅក្រម |
| ៣-លោក | ជីវ | កេង | ជាចៅក្រម |
| ៤-លោក | ប្រាក់ | គីមសាន | ជាចៅក្រមរបាយការណ៍ |
| ៥-លោក | គង់ | ភីរុន | ជាចៅក្រម |

ក្រឡាបញ្ជី

លោក **សុខ ម៉ៅ**

តំណាងមហាអយ្យការ

លោក **សាយ សារី** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ៣៥"ឈ" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៥៦២ ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **ណាលី ចិន្ត្រា** (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣៦ឆ្នាំ សញ្ជាតិកាណាដាបារាំង មុខរបរនាយិកាចាត់ការទូទៅនៃអង្គការលីកាដូ ទីលំនៅផ្ទះលេខ១០៣ ផ្លូវលេខ ៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះឃុន ណាទេព"ស" ម្តាយឈ្មោះពង្ស ឈីវហ្គេច"រ" នៅលើរ ។

មានមេធាវីលោក យុង ផានិត ។

ចុងចម្លើយឈ្មោះ **ខុម សើរ** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ

មុខរបរប្រធានមជ្ឈមណ្ឌលកុមារកំព្រាអាស៊ី ទីលំនៅផ្ទះលេខ ១៣០ ក្រុមទី៣២ សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះអ៊ុម វ៉ាន់ខន "ស" ម្តាយឈ្មោះពុធ សាន "ស" ប្រពន្ធឈ្មោះយោ សុផល្លី មានកូន០៣នាក់ ។

មានមេធាវីលោក ឈិត បូរ៉ាវុធ ។

តតិយជនឈ្មោះ **កែវ ស៊ុនហេង** (តំណាងឱ្យក្រសួងសង្គមកិច្ច) ។

**កម្មវត្ថុបណ្តឹង** : ប្តឹងសុំដកហូតអំណាចមេបា ឬ អាណាព្យាបាលលើកុមារចំនួន១២រូប .

បានឃើញបណ្តឹងសាទុក្ខលេខ ១៤២ ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០៣ របស់ឈ្មោះយ៉ុង-ផានិត ជាមេធាវីតំណាងឱ្យឈ្មោះ ណាលី ពីឡូក ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣៥"ឈ"ចុះថ្ងៃទី២៦ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២០០ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២១-៩-២០០១ របស់ដើមចោទឈ្មោះណាលី ពីឡូក ជានាយិកាចាត់ការទូទៅនៃអង្គការលីកាដូ បញ្ជាក់ថា អ្នកស្រីដើង ភាព អាយុ៣១ឆ្នាំ ស្នាក់នៅផ្ទះជួលបានបាត់កូន០២នាក់ ឈ្មោះថា សុផាន់មៃ ភេទស្រី អាយុ៣ឆ្នាំ និងឈ្មោះថា វុទ្ធី ភេទប្រុស អាយុ០១ឆ្នាំ កូនគាត់ទាំងពីរនាក់នោះ ត្រូវស្រីម្នាក់មិនស្គាល់ឈ្មោះមកលួងលោម ដើម្បីយកទៅពិនិត្យឈាមមើលជំងឺអេដស៍ ។ ក្រោយពីពិនិត្យដឹងថា : គ្មានជម្ងឺអេដស៍ ស្ត្រីនោះបានប្រាប់អ្នកស្រី ដើង ភាព ថា ក្មេងទាំងពីរនោះបានឱ្យទៅឈ្មោះ ចាន់ សារឿន ភេទប្រុស អាយុ៣២ឆ្នាំ ស្នាក់នៅផ្ទះលេខ១៩១ ក្រុមទី៣៧ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ ជាអ្នកចិញ្ចឹម ហើយគេនឹងយកទៅអាមេរិកដោយស្ត្រីនោះបានឱ្យលុយទៅអ្នកស្រីដើង ភាព ចំនួន៦០ម៉ឺនរៀល តែអ្នកស្រីមិនព្រមទទួលយក ហើយទាមទារយកកូនទាំងពីរនាក់នោះវិញ ។ នៅថ្ងៃទី០៣-៩-២០០១ អ្នកស្រីដើង ភាពនិងតំណាងអង្គការម៉ារីណុល ម្នាក់បានប្តឹងមកអង្គការលីកាដូ ឱ្យជួយរកកូនគាត់ទាំងពីរនាក់ ។

បន្ទាប់ពីការជួយអន្តរាគមន៍ពីសមត្ថកិច្ចបានឆែកឆេរ ផ្ទះលេខ ១៩១ +៥១ មិនឃើញក្មេងទាំងពីរនាក់នោះទេ បែរជាឃើញកុមារ និងទារកចំនួន១៣នាក់ទៅវិញ តែបានប្រគល់កុមារម្នាក់ឱ្យសមត្ថកិច្ច ហើយសមត្ថកិច្ចបានឃាត់មនុស្សបួននាក់ ។ ឯកុមារ និងទារកចំនួន១២នាក់ដោយពុំទាន់មានអ្នកគ្រប់គ្រងត្រឹមត្រូវ គណៈកម្មការត្រួតពិនិត្យឆែកឆេរ បានប្រគល់កុមារ និងទារកនោះអង្គការលីកាដូ គ្រប់គ្រងបណ្តោះអាសន្ន ។ នៅថ្ងៃទី០៤-៩-២០០១ ឈ្មោះយូ សាខន តំណាងឱ្យមណ្ឌលកុមារកំព្រាអាស៊ីបានយកក្មេង០២នាក់ ជាកូនរបស់អ្នកស្រីដើង ភាព នៅអធិការនគរបាលខណ្ឌទួល

គោក ប្រគល់ឱ្យអ្នកស្រីជើង ភាពវិញ ។

នៅថ្ងៃទី១០-៩-២០០១ លោកព្រះរាជអាជ្ញា សុខ រឿន បានចារឯកភាពលើលិខិតស្នើសុំរបស់មណ្ឌលកុមារអាស៊ីសុំយកកុមារ និងទារកចំនួន១២នាក់នោះ ទៅឱ្យមណ្ឌលកុមារកំព្រាអាស៊ីវិញ ដោយកុមារ និងទារក ពុំមានការថែរក្សាត្រឹមត្រូវ ខ្លះមានជំងឺយ៉ាងធ្ងន់ធ្ងរ មិនត្រូវបានគេមើលព្យាបាលជំងឺ ម្យ៉ាងទៀត ដោយកុមារ និង ទារក ទាំងនោះកំពុងជាប់ពាក់ព័ន្ធ នឹងករណីជួញដូរកុមារ ដែលមណ្ឌលកុមារកំព្រាអាស៊ីយកលាក់ទុកក្នុងផ្ទះលេខ ១៨១ + ៥១ និងដើម្បីស្វែងរកឪពុកម្ដាយពិតប្រាកដគឺដោយសហការជាមួយក្រសួងសង្គមកិច្ចការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដូច្នេះអង្គការលីកាដូ ប្ដឹងសុំដកហូតអំណាចមេបា ឬអាណាព្យាបាលកុមារ និងទារក១២នាក់ពីមណ្ឌលកុមារកំព្រាអាស៊ី ដើម្បីប្រយោជន៍កុមារ និងទារកទាំង១២នាក់ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២៧"ក" ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី២១-៩-២០០១ របស់អង្គការលីកាដូ និងសេចក្ដីសន្និដ្ឋានការពាររបស់មេធាវីយុង ផានិត ចុះថ្ងៃទី២៤-៣-២០០២ និងចំលើយនៅពេលសវនាការមានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ តែផ្ទុយនឹងគតិច្បាប់ តុលាការសំរេចបដិសេធចោល ។

២-សំរេចប្រគល់កុមារនិងទារកទាំង១២រូបក្នុងរឿងនេះ ឱ្យទៅសមាគមកុមារកំព្រាអាស៊ី ជាអ្នកគ្រប់គ្រងកុមារទាំង១២រូប តាមច្បាប់ តាមអនុស្សរណៈរបស់ខ្លួន ដែលបានចុះជាមួយក្រសួងសង្គមកិច្ចការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩

៣-តំរូវឱ្យសមាគមកុមារកំព្រាអាស៊ីអនុវត្តតាមលក្ខខ័ណ្ឌនៃអនុស្សរណៈដែលបានព្រមព្រៀងជាមួយក្រសួងសង្គមកិច្ចការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទាកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ឱ្យបានសុក្រិត្យតទៅ ដើម្បីជួយសំរួលបន្ទុករាជរដ្ឋាភិបាលកម្ពុជា និងដើម្បីផលប្រយោជន៍ដល់សង្គមកម្ពុជា និងជូនសង្គមមនុស្សជាតិទាំងមូល ។

៤-អំពីជម្ងឺចិត្តដែលចុងចម្លើយប្ដឹងសុំពីភាគីដើមចោទចំនួន ដប់លានរៀល សំរេចតំរូវឱ្យដើមចោទបង់ប្រាក់ជម្ងឺចិត្តឱ្យចុងចម្លើយចំនួនប្រាំលានរៀល សុំលើសពីនេះបដិសេធចោល ។

៥-សំរេចរឹបអូសប្រាក់ប្រដាប់ក្ដី ៧.០០០៛ ពីអង្គការលីកាដូ ជាដើមចោទដែលបង់រួចជាស្រេច ដាក់ចូលថវិការដ្ឋ និងចំណាយផ្សេងៗរួចហើយ ។

៦-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងមេធាវីដើមចោទ ចំពោះមុខមេធាវីជាតំណាងចុងចម្លើយ ចំពោះមុខតតិយជន តំណាងក្រសួងសង្គមកិច្ច សំរេចបើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ របស់ឈ្មោះនួន សុខជា ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ២៧"ក" ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០២ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៦៨"ឈ" ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៩-៦-២០០២ របស់ឈ្មោះនួន សុខជាទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ២៧"ក" ចុះថ្ងៃទី២៤-៤-២០០២ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្វ្លឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥.០០០៛ និងលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

៤-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៦-៩-២០០២ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣-១០-២០០២ កំបាំងមុខគូក្ដី បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់លេខ ១៨៧ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ របស់ឈ្មោះយុង ផានិត ជាមេធាវីការពារឱ្យដើមចោទ ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៦៨"ឈ" ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣៥ "ឈ" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងទាស់ចុះថ្ងៃទី១៨-១២-២០០២របស់លោកមេធាវីយុងផានិតទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តំកល់សាលដីកាកំបាំងមុខលេខ ១៦៨"ឈ" ចុះថ្ងៃទី០៣-១០-២០០២ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី២៥-០២-២០០៣ ចំពោះមុខដើមចោទ មេធាវីការពារចុងចម្លើយ និងតតិយជន កំបាំងមុខចុងចម្លើយ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦-០២-២០០៣ ចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ១៤២ ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០៣ របស់ឈ្មោះយ៉ុង-ផានិត ជាមេធាវីតំណាងឱ្យឈ្មោះ ណាលី ពីឡូក ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ

៣៥"ឈ"ចុះថ្ងៃទី២៦ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល។

បានឃើញសារណាការពារចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៣ របស់មេធាវីយុង ផានិត ។

បានឃើញសារណាតប ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះពុធ សេរី ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ៣៥ "ឈ" ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ បានសំរេចសេចក្តីមានលក្ខណៈត្រឹម-ត្រូវតាមទំរង់ និងគតិច្បាប់ហើយ សូមក្រុមប្រឹក្សាជំនុំជំរះសំរេច ។

បានស្តាប់ចំលើយរបស់អ្នកស្រីពុង ជីកេត តំណាងឱ្យដើមចោទ នាពេលសវនាការថា : ពេលប៉ូលីស និងព្រះរាជអាជ្ញាចុះឆែក បានឃើញកុមារចំនួន១១នាក់ តួច២ AOA ថា មិនសុខចិត្តទេ ពេលប៉ូលីសឱ្យអង្គការខ្លួនរក្សាកុមារ បានយកផ្ញើនៅកន្លែងមួយស្អាតពិតមែន កន្លែងនោះ ជាកន្លែងព្យាបាលអេដស៍ តែស្អាតណាស់ មានទីធ្លាទូលាយ អាចឱ្យក្មេងរត់លេងបាន ដោយកុមារពីរនាក់មានជំងឺធ្ងន់ យាយជី ក៏បានយកទៅព្យាបាលជំងឺរបេងសួត កុំបានអង្គការលីកាដូយកទាន់ កុំអីពិបាកហើយ ។ កូនក្មេង ១២នាក់ ក្រោយមកពេលផ្ទៀងផ្ទាត់បញ្ជីឈ្មោះទៅ ឃើញថា មិនត្រូវគ្នា ខុសថ្ងៃខែឆ្នាំ ឯបញ្ជីមួយទៀត ក្រសួងសង្គមកិច្ចផ្ញើមកខុសគ្នាទៀត ពេលតុលាការបញ្ជាឱ្យយកកូនក្មេងសងវិញ អង្គការលីកាដូសងភ្លាម បើមិនឱ្យលីកាដូមើលទេ ខ្លួនមិនសុខចិត្តត្រង់តុលាការក្រោមបង្គាប់ឱ្យខ្លួនបង់ជំងឺចិត្ត សព្វថ្ងៃអន្តរជាតិគេថ្កោលទោសយើងណាស់ ដោយសារមានជនខិលខូច យកកុមារទៅលក់នៅបរទេស ។ ហើយតាមវែបសាយគេរកឃើញថា មានការជួញដូរកុមារ ហើយស្រីជាជាតិអាមេរិកកាំងពីរនាក់ គេចោទប្រកាន់ហើយ ពីបទលក់កូន សូមកុំថាលីកាដូបង្ខូចឈ្មោះខ្លួនជឿថា តុលាការចៅក្រម៥រូបនេះ និងពិចារណារកយុត្តិធម៌មិនខាន ។

បានស្តាប់ចំលើយរបស់ឈ្មោះពុធ សេរី នាពេលសវនាការថា : ខ្លួនតំណាងឱ្យអង្គការកុមារកំព្រាអាស៊ីលីកាដូបានប្តឹងពីអង្គការខ្លួនបីដងហើយ ជំងឺចិត្តនេះ តិចតួចណាស់ ខ្លួនទារដើម្បីយកទៅឧបត្ថម្ភកុមារ ព្រោះលីកាដូ ជាអ្នករំលោភច្បាប់ ពីផ្ទះផ្ញើកុមារទៅមណ្ឌលប្រហែលពី១០ ទៅ១៥គមផ្ទះនោះ ជាផ្ទះពេទ្យឯកជន ម្ចាស់ផ្ទះផ្ញើពេទ្យនៅកុមារមជ្ឈឹម មានដាក់ផ្លាកពេទ្យដែរ ឯការរកឈ្មោះឪពុកម្តាយចិញ្ចឹមឱ្យកុមារតាមរយៈក្រសួងសង្គមកិច្ច ខ្លួនមិនដែលស្គាល់វែបសាយទេ នៅអង្គការខ្លួនសព្វថ្ងៃ មានក្មេងសរុប ១១នាក់ និង១២ នាក់ផង សព្វថ្ងៃក្មេងទាំង ១២នាក់នេះនៅក្នុងមណ្ឌលទាំងអស់ ។

បានស្តាប់ចំលើយរបស់ឈ្មោះឆែម ស៊ុនហេង នាពេលសវនាការថា : ខ្លួនតំណាងឱ្យសង្គមកិច្ច តាមការចុះពិនិត្យគ្រប់មណ្ឌលកុមារកំព្រាឃើញថា AOA ធ្វើការល្អ មានសាលារៀន ភារហូប

ចុករបស់កុមារ ទោះឆ្ងាញ់ មិនឆ្ងាញ់ ឃើញថា មានសភាពសមរម្យ ការចុះពិនិត្យ ជាធម្មតាមួយខែធ្វើបានតែម្តងទេ ចំពោះមណ្ឌលមួយសព្វថ្ងៃមានមណ្ឌលទាំងអស់៦០ មណ្ឌលកុមារកំព្រាមានចំនួន៨ក្រៅពីនោះជាមណ្ឌលអប់រំផ្សេង១ទៀត ។ ខ្លួនយល់ថា ពុំគួរចាំបាច់ជណ្តើមគ្នាទេ មានអ្នកគ្រប់គ្រងនិងអាណាព្យាបាលរួចទៅហើយ ។

បានស្តាប់ចំលើយរបស់ឈ្មោះ ពង់ ជីកេត តំណាងឱ្យដើមចោទ នាពេលសវនាការថា : ខ្លួនមិនចោទ AOA ទេ ទោះបីមេធាវីខ្លួននិយាយគ្មានភស្តុតាងមែន តែវែបសាយ និង កាសែតមានចុះផ្សាយ ឯមេធាវីគ្រាន់តែធ្វើសេចក្តីសន្និដ្ឋានប៉ុណ្ណោះ ខ្លួនសូមជូនភស្តុតាងពេលចុះទៅ គេថតបានពីកុមារនេះ ក្រោយមកកុមារពីរនាក់យាយជីយកទៅព្យាបាល ខ្លួនមានកាសែតវីដេអូ ជាភស្តុតាងអ្នកស្រី ដើង ភាព មកប្តឹងលីកាដូ ថា មានគេមកលួងលោមគាត់ថា យកកូនឱ្យគាត់វិញ ទើបគាត់មកប្តឹង ទើបលីកាដូសុំដីកាពីព្រះរាជអាជ្ញា ចុះសហការណ៍ជាមួយប៉ូលីស ឆែកឃើញកុមារ ហើយកុមារពីរនាក់ក៏បានប្រគល់ឱ្យម្តាយគេវិញ ហើយគួរឱ្យឆ្ងល់ថា កុមារទាំងនោះ មានមួយទើបកើតបានប៉ុន្មានថ្ងៃប៉ុណ្ណោះ តើគេចិញ្ចឹមម្តេចកើត លីកាដូ មិនដែលនិយាយទេ គ្រាន់តែឃើញតាម អាំងទែណែតដែលនរណាក៏មានសិទ្ធិមើលដែរ បើ AOA ទៅប្តឹងពីអាំងទែណែត និង កាសែតវិញ ទើបជាការត្រឹមត្រូវ ។ ខ្លួនបានទាក់ទងអង្គការមួយទទួលចិញ្ចឹមរួចហើយ តែអកុសល តុលាការសំរេចឱ្យប្រគល់ក្មេងឱ្យ AOA វិញ ខ្លួនគោរពហើយ ឯកន្លែងផ្ទះដែលឆែកឃើញ ពុំមានផ្លាកសញ្ញាចោទទេ ខ្លួនមិនចង់ជ្រៀតជ្រែកមណ្ឌលកុមារទេ តែអ្នកកាសែតចង់ចូលមិនបាន ហើយបើកុមារទាំង១២នាក់នោះមិនមែនជារបស់ AOAទេ ខ្លួនក៏មិនខ្វល់ដែរ ព្រោះខ្លាចគេចិញ្ចឹមក្មេងនោះមិនបានល្អ ឯក្មេងខ្លះអាយុ៨ឆ្នាំ មិនបានរៀនសូត្រ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់ឈ្មោះ ឈិត បូរ៉ារុធ ជាមេធាវីការពារឱ្យចុងចម្លើយនាពេលសវនាការថា : ខ្លួនសូមបញ្ជាក់ពីជំងឺចិត្ត AOAមិនចង់ប្តឹងទារពីលីកាដូទេ ជំងឺចិត្តនេះក្នុងនាមខ្លួនជាមេធាវីស្ម័គ្រចិត្ត សូមបញ្ជាក់ថាមិនបាច់យកជាលុយទេ ឱ្យជាអង្ករ ទឹកដោះគោ ចំណីអាហារផ្សេងៗក៏បាន ហើយអញ្ជើញឱ្យលីកាដូចូលរួមដែរ ។ ការផ្សាយពត៌មានដូចយើងដឹងហើយតាមរយៈCNN តើវាខ្មាសខ្មាស់ប៉ុណ្ណា រឿងវែបសាយ គួរមានការស៊ើបអង្កេតឱ្យបានច្បាស់លាស់AOA ធ្វើសកម្មភាពតាមក្រសួងសង្គមកិច្ច ពេលមានការសុំកូនពីបរទេស AOA ក៏មិនដែលជាប់ពាក់ព័ន្ធនិងការលក់ក្មេងទេ។

ខ្លួនពុំមានសេចក្តីសន្និដ្ឋានវែងឆ្ងាយទេ បើប្តឹងម្តេចក៏មិនសុំដកអំណាចមេបាពីក្មេងទាំងអស់ជាង១០០នាក់ តែម្តងទៅ ដើម្បីឱ្យចុងចម្លើយបិទមណ្ឌល ដោយសារមានរឿងក្តីធ្វើឱ្យម្ចាស់ជំនួយរាថយ ហើយមណ្ឌលសព្វថ្ងៃមានឧបសគ្គក្នុងការផ្គត់ផ្គង់ក្មេងៗ ។

រឿងព្រហ្មទណ្ឌតុលាការ បានលើកលែងចោទប្រកាន់ទៅហើយ ម្តេចក៏មិនប្តឹងឧទ្ធរណ៍ផង

ទុកឱ្យស្ថាពរធ្វើអ្វី ?

នៅខែវិច្ឆិកាអនុសារនៈ ប្រហែលជាចប់ ហើយ AOA ប្រហែលប្រគល់មណ្ឌលកុមារអោយសង្គមកិច្ច ដូចនេះបើលីកាដូចង់ គឺមានឱកាសហើយ ។

ខ្លួនសូមសរុបសេចក្តីសន្និដ្ឋានគឺ :

១-ការប្តឹងដកអំណាចមេបា គឺលីកាដូ ធ្វើមិនត្រឹមត្រូវទេ

២-ជំងឺចិត្តទារ ៥.០០០.០០០៛ ឱ្យជាអង្ករ ទឹកដោះគោ ម្ហូបអាហារ ក៏បាន ។

<u>សំណូមពរ</u> : សុំតុលាការកំពូលតំកល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការដដែល ។

បានស្តាប់ចំលើយរបស់ឈ្មោះ ពង់ ជីកេត បន្ថែមទៀតថា : លីកាដូគោរពច្បាប់ណាស់ កុមារបានយកឱ្យ AOA វិញហើយ សូមតុលាការសំរេចចុះ បើតុលាការទុកកុមារឱ្យAOA ក៏ទុកចុះតែសុំឱ្យតំណាងលីកាដូទៅមើលផងថា កុមារទាំងនោះទៅដល់ណាហើយ បានរៀនសូត្រទេ ។ ខ្លួនមិនហ៊ានសំរេចលើកុមារ១២នាក់នោះទេ ស្រេចលើតុលាការកំពូលសំរេចចុះ ខ្លួនយល់ថា មានអង្គការផ្សេងៗទៀតល្អ ខ្លួនបានទាក់ទង គេព្រមទទួល ហើយមិនដែលជាប់ពាក់ព័ន្ធនឹងការជួញដូរទៀតផង បើយល់ថា លីកាដូល្អ សំរេចឱ្យលីកាដូ ខ្លួនយកទៅផ្ញើគេ ព្រោះមានអង្គការផ្សេងទៀតល្អមើលថែទាំបានត្រឹមត្រូវ ។

លោកយ៉ុង ផានិត ជាមេធាវីការពារឱ្យអ្នកស្រីពង់ ជីកេត បានធ្វើសេចក្តីសន្និដ្ឋានថា : ពាក់ព័ន្ធនឹងលីកាដូប្តឹងសុំដកអំណាចមេបាលើក្មេង១២នាក់ពី AOA ដោយសារមានបញ្ហាច្រើនគឺ :

១-មានការបន្លំ ហើយAOA ធ្វើផ្ទុយពីអនុសារនៈ ត្រង់មាត្រា៣ AOA ថា ទទួលយកតែលេក្មេងអនាថា និងកុមារកំព្រាប៉ុណ្ណោះ តែជាក់ស្តែងបែរជាយកក្មេងដែលមានការពាក់ព័ន្ធ មានម្តាយឪពុក មកចិញ្ចឹមដែរ ។

២-AOAថែទាំកុមារមិនបានល្អ យកក្មេងទៅព្យាបាល មិនមែនជាឃ្លីនិក និងមិនបានឱ្យក្មេងចូលរៀន ។

៣-អ្នកសារពត៌មានរកឃើញថា AOA ចិញ្ចឹមក្មេងដើម្បីធ្វើអាជីវកម្ម និងរកចំណូលដូចចុងចម្លើយលើកឡើងពេលនេះហើយថា លីកាដូ ប្តឹងគាត់ ធ្វើឱ្យគាត់ខាត ។

លីកាដូគ្រាន់តែមិនចង់ឱ្យគេរំលោភសិទ្ធិកុមារ និងធ្វើអាជីវកម្មលើកុមារប៉ុណ្ណោះ ហើយជួយក៏មិនដែលនឹកចង់បានផលប្រយោជន៍អ្វីទៅចំពោះសំណងជំងឺចិត្តមិនគួរឱ្យលីកាដូបង់ទេ ព្រោះលីកាដូធ្វើដើម្បីប្រយោជន៍សង្គមប៉ុណ្ណោះក៏ដូចប្រយោជន៍ប្រទេសជាតិ លីកាដូធ្វើយ៉ាងនេះយ៉ាងហោចណាស់ធ្វើឱ្យសង្គមដឹងថាAOA គ្រប់គ្រងកុមារ និង ថែទាំកុមារមិនបានល្អដែរ ។

សូមពិចារណាលើសំណុំរឿងនេះនិងបញ្ជូលសំណុំរឿងឱ្យសាលាឧទ្ធរណ៍ស៊ើបអង្កេតឡើងវិញ

សំណាង សុំបដិសេធចោល ។

លោក ឈិត ប៊ូរ៉ាវុធ ជាមេធាវីការពារឱ្យចុងចម្លើយបានបន្ថែមទៀតថា : ចំពោះរឿងនេះ មានឯកសារច្រើនណាស់ ហើយច្របូកច្របល់ ឯការបញ្ជូនកុមារទៅព្យាបាល ចេញ-ចូល សុទ្ធតែមានលិខិតទាំងអស់ ការបញ្ជូនកុមារទៅព្យាបាល មុនកើតរឿងពីរបីថ្ងៃ បញ្ជូនចេញពីមណ្ឌលតែម្តង។ ចំពោះការស្នើសុំរបស់លីកាដូ ខ្លួនមិនយល់ព្រមទេ ព្រោះគាត់ជាអ្នកប្តឹងចោទAOA ខុស ។

បានស្តាប់ចំលើយរបស់ឈ្មោះពុធ សេរី បានបន្ថែមទៀតថា : អ្នកផ្គត់ផ្គង់លើមណ្ឌលAOA មានផលវិបាកច្រើន ផ្នែកថវិកា តែចេះសុំគេទៅ ហើយមានបុគ្គលិកខ្លះ បានបំរើការដោយមិនយកកំរៃផង យកតែបាយហូបប៉ុណ្ណោះ ។ ក្នុងមណ្ឌលមានដុកទ័រ មួយរូប គ្រូបង្រៀនមួយរូប អ្នកបើកឡាន អ្នកដាំបាយ ពេលមានទំនាស់គេលែងយកកំរៃតែម្តង ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី តតិយជន និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី.
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៤៧ ចុះថ្ងៃទី ២៦ ខែ មិនា ឆ្នាំ២០០៣ របស់លោក យុង ផានិត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់លោក យុង ផានិត ក្នុងសារណាចុះថ្ងៃទី០២-០៧-២០០៣ ថា អង្គការលីកាដូ ដែលមានការអនុញ្ញាតពីក្រសួងមហាផ្ទៃត្រឹមត្រូវ ដែលអាចនិយាយបានថា ជាអង្គការមហាជន មានសិទ្ធិយ៉ាងពេញលេញក្នុងការប្តឹងដកហូតអំណាចមេបា ឬអាណាព្យាបាល នោះគឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :

. អង្គការលីកាដូ ជាអង្គការក្រៅរដ្ឋាភិបាល ពុំអាចនិយាយបានថា ជាអង្គការមហាជនដូចមានចែងក្នុងមាត្រា ១២០ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារទេ ។

. អង្គការលីកាដូ គ្រាន់តែមានច្បាប់អនុញ្ញាតពីក្រសួងមហាផ្ទៃតែប៉ុណ្ណោះ ប៉ុន្តែពុំបានចុះអនុស្សារណៈជាមួយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាក្នុងការទទួលយក និងថែទាំទារក ទារិកា កុមារកំព្រា និងក្មេង អនាថា មកដាក់ក្នុងមណ្ឌលរបស់ខ្លួន

ឡើយ ។

- យល់ឃើញថា ការដែលមេធាវីដើមចោទលើកឡើងថា ចុងចម្លើយថែទាំកុមារមិនបានល្អ ហើយធ្វើអាជីវកម្មយកចំណេញពីលើកុមារនោះគឺជាការសន្និដ្ឋានខុសពីការបញ្ជាក់របស់តំណាងក្រសួងសង្គមកិច្ចការងារ និងយុវនិតិសម្បទា ។

- យល់ឃើញថា ការលើកឡើងរបស់លោកយ៉ុង ផានិត ថា សមាគមកុមារកំព្រាអាស៊ី ពុំបានអនុវត្តឱ្យបានត្រឹមត្រូវទៅតាមអនុស្សរណៈ ដែលបានព្រមព្រៀងជាមួយក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនិតិសម្បទាទេនោះ គឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថា :

. អង្គការលីកាដូ ពុំមែនជាភាគីនៃការចុះហត្ថលេខាក្នុងអនុស្សរណៈឡើយ ។

. នាសវនាការនៅសាលាឧទ្ធរណ៍ ក៏ដូចចម្លើយនៅចំពោះតុលាការតំណាងក្រសួងសង្គមកិច្ចការងារ ដែលជាហត្ថលេខីនៃអនុស្សរណៈ និង ជាអាណាព្យាបាល ក៏បានទទួលស្គាល់ផងដែរថា ការដែលអង្គការលីកាដូប្តឹងតវ៉ានោះ គឺមិនត្រឹមត្រូវទេ ព្រមទាំងបានទទួលស្គាល់ថា ប្រសិនបើអង្គការកុមារកំព្រាអាស៊ី ប្រតិបត្តិការខុសមែននោះ ក្រសួងមានសិទ្ធិបញ្ឈប់ជាបន្ទាន់ ។

- យល់ឃើញថា ការដែលតុលាការក្រុងភ្នំពេញ និងសាលាឧទ្ធរណ៍សំរេចឱ្យដើមចោទសងជំងឺចិត្ត ៥លានរៀលទៅចុងចម្លើយ គឺពុំមានសំអាងហេតុទេ ។ ដូច្នេះតាមមាត្រា ២០៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលបានអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ តុលាការកំពូលគប្បីទុកជាមោឃៈ និងបង្វិលឱ្យសាលាឧទ្ធរណ៍ជំនុំជំរះជាថ្មីឡើងវិញ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៣៥"ឈ"ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ហើយ លើកលែងតែប្រាក់ជំងឺចិត្ត ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូភាគី និង តតិយជន

១-ទទួលបណ្តឹងសាទុក្ខលេខ១៤២ចុះថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០៣ របស់លោកយ៉ុងផានិត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ៣៥ "ឈ" ចុះថ្ងៃទី២៦-០២-២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែប្រាក់ជំងឺចិត្តដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ២០០ ចុះថ្ងៃទី២៦-៥-២០០៣ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះត្រង់ប្រាក់ជំងឺចិត្ត ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលលោក ពុធ សេរី បានបង់ជួស គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ .

ហើយតំរូវឱ្យដើមចោទសងប្រាក់ចំនួន ១៩.០០០៛នេះទៅឱ្យចុងចម្លើយវិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៤ ។